**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: មេធាវីការពារក្តី អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 10-Feb-2012, 15:18
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ញត្តិ របស់អៀង សារី ស្នើសុំលុបចោលការសុំការអនុញ្ញាតរបស់សហព្រះរាជអាជ្ញា ដើម្បីឆ្លើយតប និងការឆ្លើយតបទៅនឹងចម្លើយតបរបស់ អៀង សារី ទាក់ទិននឹងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១**

---

**ដាក់ដោយ ÷**

**មេធាវីការពារក្តី ÷**

អាង ឧត្តម

Michael G. KARNAVAS

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ÷**

ចៅក្រម **និល ណុន**

ចៅក្រម **យ៉ូរ ឧត្តរា**

ចៅក្រម **យ៉ា សុខន**

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **ធូ មណី**

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា ៖**

ជា លាង

Andrew CAYLEY

**មេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីការពារក្តីរបស់លោក “មេធាវីការពារក្តី” ចាប់ពីពេលនេះសូមស្នើសុំលុបចោលការសុំការអនុញ្ញាតរបស់សហព្រះរាជអាជ្ញា ដើម្បីឆ្លើយតប និងការឆ្លើយតបទៅនឹងចម្លើយតបរបស់ អៀង សារី ទាក់ទិននឹងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១[១]។ ញត្តិនេះត្រូវបានរៀបចំឡើងជាចាំបាច់ ពីព្រោះសហព្រះរាជអាជ្ញាបានរំលោភបំពានសេចក្តីណែនាំយ៉ាងច្បាស់លាស់របស់អង្គជំនុំជម្រះសាលាដំបូងដែលបញ្ជាក់ថា “ភាគីមិនអាចដាក់ការឆ្លើយតបណាមួយដោយគ្មានការអនុញ្ញាតពីអង្គជំនុំជម្រះជាមុនទេ”[២]។ បើសិនសហព្រះរាជអាជ្ញាបានធ្វើតាមការណែនាំ ប្រហែលជាមិនចាំបាច់ដាក់សំណើសុំនេះ ដោយសំអាងភាពគួរអោយអាណិតអាសូរនៃការអះអាងរបស់សហព្រះរាជអាជ្ញា។

១. អង្គជំនុំជម្រះសាលាដំបូងបានណែនាំដល់ភាគីទាំងអស់ថា “សំណើសុំការអនុញ្ញាតអាចធ្វើបានតាមរយៈសារអេឡិចត្រូនិកដោយផ្ញើទៅកាន់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ដោយរៀបរាប់ត្រួសៗអំពីបញ្ហានានាដែលភាគីយល់ថាចាំបាច់ត្រូវដោះស្រាយនៅក្នុងការឆ្លើយតបនោះ”[៣]។

---

[១] ការសុំការអនុញ្ញាតរបស់សហព្រះរាជអាជ្ញា ដើម្បីឆ្លើយតប និងការឆ្លើយតបទៅនឹងចម្លើយតបរបស់ អៀង សារី ទាក់ទិននឹងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១ ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E163/2 (“ការសុំការអនុញ្ញាតដើម្បីឆ្លើយតប និងការឆ្លើយតប”)។

[២] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំដែលមានឯកសារលេខ E91/2, E95/7, E99/1/1, E100/4/1, E101/3, E114/2, E119 និងការឆ្លើយតបទៅនឹងសំណើសុំឱ្យមានការណែនាំជាទូទៅអំពីការដាក់ការឆ្លើយតប (ឯកសារលេខ E112), ថ្ងៃទី ៥ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E126 ទំព័រ ១។

[៣] *ដូចខាងលើ*។

សហព្រះរាជអាជ្ញាបានដឹងពីនីតិវិធីនេះ ដោយខ្លួនធ្លាប់បានប្រើប្រាស់នីតិវិធីនេះកាលពីមុនរួចហើយ។ តាមពិត សហព្រះរាជអាជ្ញាបានទទួលការព្រមានដោយជាក់លាក់ពីសំណាក់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងឲ្យធ្វើការបញ្ជូនសំណើសុំការអនុញ្ញាតដើម្បីឆ្លើយតបទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងដោយផ្ទាល់ និងមិនត្រូវបញ្ជូនសំណើសុំការអនុញ្ញាតដើម្បីឆ្លើយតបទៅចៅក្រមឡើយ[៤]។ មេធាវីការពារក្ដី សន្មតថា សហព្រះរាជអាជ្ញា មិនបានស្នើសុំការអនុញ្ញាតដើម្បីធ្វើការឆ្លើយតប ពីសំណាក់មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ព្រោះហេតុថាមេធាវីការពារក្ដី មិនបានទទួលការជូនដំណឹងអំពីរឿងនេះ ហើយហេតុថា សហព្រះរាជអាជ្ញា បានស្នើសុំការអនុញ្ញាតដើម្បីឆ្លើយតបនៅក្នុងសារណាររបស់ខ្លួន។

២. ទោះបីជាសហព្រះរាជអាជ្ញាបានអនុវត្តតាមនីតិវិធីយ៉ាងត្រឹមត្រូវក៏ដោយ ក៏ក្នុងករណីនេះមិនចាំបាច់ត្រូវមានការឆ្លើយតបណាមួយឡើយ ទោះបីជាមានការអះអាងរបស់សហព្រះរាជអាជ្ញាដែលថាចាំបាច់ត្រូវមានការឆ្លើយតបដោយសារតែ "មានការបកស្រាយខុសយ៉ាងធ្ងន់ធ្ងរ"របស់មេធាវីការពារក្ដី ឧទាហរណ៍ សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំអោយមានការពិចារណាឡើងវិញនូវដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី។ ដោយមិនគិតអំពីចំណងជើងនៃសារណារបស់សហព្រះរាជអាជ្ញា តាមពិត សហព្រះរាជអាជ្ញា ពិតជាព្យាយាមទៅអោយហួសឆ្ងាយលើសពីកថាខណ្ឌ ៤ នៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដែលឥឡូវសហព្រះរាជអាជ្ញាអះអាងថាវាស្ថិតនៅក្នុងរង្វង់ដែនកំណត់ ដែលតាមរយៈនោះ សហព្រះរាជអាជ្ញាបានទទួលការណែនាំ អោយដាក់សារណាផ្សេងមួយថែមទៀត ដែលពង្រីកវិសាលភាព និងទៅហួសដែនកំណត់ដែលដាក់ដោយអង្គជំនុំជម្រះសាលាដំបូង សម្រាប់សំណុំរឿង ០០២/១។

៣. ទាក់ទងនឹងការណែនាំដល់អង្គជំនុំជម្រះសាលាដំបូងអំពីក្រមសីលធម៌សម្រាប់មេធាវី មេធាវីការពារក្ដី បានធ្វើការកត់សម្គាល់ដោយបានដាក់ពាក្យពេចន៍របស់សហព្រះរាជអាជ្ញាឲ្យមានទម្រង់ផ្ដេកដើម្បី

---

[៤] "យើងក៏បានស្នើសុំលោកឲ្យដកចេញឈ្មោះចៅក្រមពីការប្រាស្រ័យទាក់ទងដូចនេះនៅពេលអនាគត ដែលការធ្វើដូចនេះគឺជាការបំពានច្បាស់លាស់លើសេចក្ដីណែនាំពីពេលមុនដែលបានផ្ញើជូនដល់ភាគីទាំងអស់"។ សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងផ្ញើជូនទៅការិយាល័យសហព្រះរាជអាជ្ញា នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១។

បង្ហាញឲ្យច្បាស់ថា ពាក្យពេចន៍ទាំងនេះគ្មានអំណាចផ្លូវច្បាប់ទេ។ ជាងនេះទៀត ពាក្យពេចន៍ទាំងនេះត្រូវបានបង្ហាញដោយចេតនាដើម្បីឲ្យសហព្រះរាជអាជ្ញា ដែលបានស្នើសុំម្តង ហើយម្តងទៀតឲ្យដាក់ទណ្ឌកម្ម ដែលនេះជាការប៉ុនប៉ងក្នុងការទប់ស្កាត់មេធាវីការពារក្តីមិនឲ្យជំទាស់ទៅនឹងបញ្ហាស្របច្បាប់[៥] អាចស្គាល់ពាក្យពេចន៍របស់ខ្លួនទាំងនេះបានដោយងាយ។

៤. ផ្ទុយទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញាដែលថា ចម្លើយតបនេះ[៦] គឺ "គ្រាន់តែជាការឆ្លើយដាក់អ្នកផ្សេង *(tu quoque)*"នោះ[៧] ជាការសំខាន់ត្រូវធ្វើការបញ្ជាក់ឡើងវិញថា សហព្រះរាជអាជ្ញាព្យាយាមម្តងហើយម្តងទៀតក្នុងការពង្រីកការជំនុំជម្រះវគ្គដំបូងនេះ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានធ្វើការប្រកាសយ៉ាងច្បាស់លាស់ថា អង្គជំនុំជម្រះសាលាដំបូងពុំមានបំណងពិនិត្យ ឬពិចារណាដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីឡើងវិញឡើយ។ ការបញ្ចុះបញ្ចូលម្តងហើយម្តងទៀតរបស់សហព្រះរាជអាជ្ញាមិនត្រឹមតែជាការមិនសមរម្យប៉ុណ្ណោះទេ តែថែមទាំងជាការបំពានដល់ដំណើរនីតិវិធី ដែលនេះជាការមិនគោរពទាល់តែសោះចំពោះការណែនាំដោយប្រុងប្រយ័ត្នរបស់អង្គជំនុំជម្រះសាលាដំបូងដល់ភាគីទាំងអស់ថា ភាគីទាំងអស់ចាំបាច់ត្រូវតែទទួលយក ឬបើមិនដូចនេះទេត្រូវប្តឹងតាមនីតិវិធីតុលាការទៅអង្គជំនុំជម្រះដែលខ្ពស់ជាងនេះ[៨]។ វាគួរឲ្យហួសចិត្តណាស់ថា

---

[៥] *សូមមើលផងដែរ* ការអនុញ្ញាតដើម្បីឆ្លើយតប និង ការឆ្លើយតប កថាខណ្ឌ ១០។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងដែលបដិសេធសំណើរបស់គាត់ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងបង្គាប់មន្ត្រីច្បាប់ជាន់ខ្ពស់របស់ខ្លួនរក្សាការប្រាស្រ័យទាក់ទងដោយចំហ និងដោយតម្លាភាពជាមួយនឹងភាគីទាំងអស់ ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១២, ឯកសារលេខ E154/1/1/2; ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះសាលាដំបូងដែលតម្រូវឲ្យជនជាប់ចោទត្រូវមានវត្តមានដើម្បីស្តាប់ការចោទប្រកាន់ និងសេចក្តីសន្និដ្ឋានបើកការចោទប្រកាន់ ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២ ឯកសារលេខ E130/4/2។

[៦] ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះលើរឿងក្តី 00២/0១ ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារលេខ E163/1។

[៧] ការសុំការអនុញ្ញាតដើម្បីឆ្លើយតប និងការឆ្លើយតប, កថាខណ្ឌ ៧។

[៨] *សូមមើលឧទាហរណ៍* សេចក្តីព្រាងប្រតិចារឹក ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ ៤ បន្ទាត់ ១៧ ដល់ ២១។ អង្គជំនុំសាលាដំបូងបានសម្រេចលើចំណុចនេះពីមុនរួចហើយ ហើយនៅពេលអង្គជំនុំជម្រះសម្រេចរួចហើយ ហើយអ្នកមិនពេញចិត្តនឹង

សហព្រះរាជអាជ្ញា មានការខឹងសម្បានៅពេលគេប្រើប្រាស់ពាក្យពេចន៍ផ្ទាល់របស់ខ្លួនទប់ទល់នឹងខ្លួន ដែលពាក្យពេចន៍ទាំងនេះគឺជាការវាយប្រហារដោយឥតអៀនខ្មាសដូចដែលខ្លួនធ្លាប់បានប្រើកន្លង មក។

**អាស្រ័យហេតុនេះ** ដោយផ្អែកលើមូលហេតុទាំងអស់ដែលបានបញ្ជាក់ខាងលើ មេធាវីការពារក្តីស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា**លុបចោល**ការសុំការអនុញ្ញាតរបស់សហព្រះរាជអាជ្ញា ដើម្បីឆ្លើយតប និងការឆ្លើយតបទៅនឹងចម្លើយតបរបស់ អៀង សារី ទាក់ទិននឹងការបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមនៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះសាលាដំបូងក៏គួរតែក្រើនរំឭកសហព្រះរាជអាជ្ញាឲ្យគោរពតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងការអនុវត្តទាំងឡាយដែលទាក់ទងនឹង សំណុំរឿង ០០២ បើទោះបីជាសេចក្តីសម្រេច និងការអនុវត្តទាំងនោះហាក់ដូចជាលំបាកក្នុងការអនុវត្តតាម ឬមិនគួរជាទីពេញចេញពីសំណាក់សហព្រះរាជអាជ្ញា ក៏ដោយ។

សូមដាក់ជូនការញត្តិនេះដោយគោរពពី ៖

| | |
|---|---|
| **អាង ឧត្តម** | **Michael G. KARNAVAS** |

សហមេធាវីការពារក្តី អៀង សារី

ចុះហត្ថលេខា នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១២

---

សេចក្តីសម្រេចនោះ អ្នកអាចប្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចនេះទៅតាមនីតិវិធីតុលាការ ហើយមិនអនុញ្ញាតឲ្យអ្នកធ្វើសេចក្តីសន្និដ្ឋានលើបញ្ហាដែលបានសម្រេចទៀតឡើយ”។